UNITED NATIONS
CAMBODIA

# ការស្តារឡើងវិញកាន់តែប្រសើរពីវិបត្តិកូវីដ-១៩ តាមរយៈទិន្នន័យប្រកបដោយគុណភាព

## ឯកសារព័ត៌មានទី ៩

**ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០២១**

ទិន្នន័យបែងចែកតាមប្រភេទ និងស្ថិតិផ្លូវការ ដែលអាចរកបានទាន់ពេលវេលា និងអាចជឿទុកចិត្តបាន មានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ការយល់ដឹងពីផលប៉ះពាល់ផ្នែកសុខភាព សង្គម និងសេដ្ឋកិច្ច ដែលបង្កឡើងដោយសារការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ និងសម្រាប់គ្រប់គ្រង ក៏ដូចជាកាត់បន្ថយផលប៉ះពាល់ទាំងនេះ។ ទិន្នន័យ និងស្ថិតិទាំងនេះ ក៏មានសារសំខាន់ និងចាំបាច់ សម្រាប់រៀបចំការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ឈរលើភស្តុតាង ចំពោះវិបត្តិនេះ ក៏ដូចជាសម្រាប់ជំរុញឱ្យមានការស្តារឡើងវិញប្រកបដោយចីរភាព និងបរិយាប័ន្ន ដែលពុំទុកនរណាម្នាក់ចោល។ ខណៈពេលដែលទិន្នន័យមានសារៈសំខាន់សម្រាប់ការតាក់តែងគោលនយោបាយ នៅក្នុង "ស្ថានភាពប្រក្រតី កន្លងមក" ការរាតត្បាតជាសកលកាន់តែរំលេចឱ្យឃើញពីសារៈសំខាន់នៃទិន្នន័យសម្រាប់សង្គ្រោះជីវិត និងស្តារឡើងវិញឱ្យកាន់តែប្រសើរ។

ប្រទេសកម្ពុជាសម្រេចបានវឌ្ឍនភាពជាច្រើន ក្នុងការបង្កើនបរិមាណទិន្នន័យ ទោះជាយ៉ាងនេះក្តីទិន្នន័យនៅមានចំណុចខ្វះខាតគួរឱ្យកត់សម្គាល់មួយចំនួន ដូចជា កម្រិតនៃការបែងចែកលម្អិតដែលចាំបាច់ វិសាលភាពភូមិសាស្ត្រ និងភាពទាន់ពេលវេលានៃទិន្នន័យជាដើម។[1] អង្គការសហប្រជាជាតិបានចាត់ទុកការផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើនគុណភាព ភាពងាយស្រួលប្រើប្រាស់ និងការបែងចែកតាមទិន្នន័យស្ថិតិលម្អិតតាមប្រភេទ ថាជាការងារអាទិភាព។ អង្គការសហប្រជាជាតិកំពុងធ្វើការងារ ដើម្បីពង្រឹងសមត្ថភាពជាតិ ក្នុងការសម្រេចគោលដៅ ដូចរៀបរាប់ខាងលើ ហើយក៏កំពុងរួមចំណែកដល់ការផលិតទិន្នន័យដែលអាចជឿទុកចិត្តបាន ដែលចាំបាច់សម្រាប់ឆ្លើយតបចំពោះបញ្ហាប្រឈមដែលបង្កឡើងដោយសារការរាតត្បាតជាសកល។ ការផ្តល់ការគាំទ្រពីអង្គការសហប្រជាជាតិក៏ផ្តោតលើការបង្កើនសមត្ថភាពជាតិក្នុងការពិនិត្យតាមដានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) និងសូចនាករថ្នាក់ជាតិដទៃទៀត ដើម្បីជំរុញការសម្រេចតាមរបៀបវារៈឆ្នាំ ២០៣០ ផងដែរ។

ស្របគ្នានឹងសកម្មភាពខាងលើនេះ អង្គការសហប្រជាជាតិកំពុងគាំទ្រដល់ក្រសួងផែនការ និងវិទ្យាស្ថានជាតិស្ថិតិ ក៏ដូចជាក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនភាពអាចរកបាន និងការប្រើប្រាស់ទិន្នន័យសម្រាប់ការអភិវឌ្ឍដោយចីរភាព ដូចជា ការផ្សារភ្ជាប់ទំនាក់ទំនងទិន្នន័យឱ្យកាន់តែប្រសើរ ជាមួយដំណើរការធ្វើផែនការ និងថវិកាជាដើម។ កន្លងមកមានការផ្តោតការយកចិត្តទុកដាក់ផ្តល់ការគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍស្ថិតិ (NSDS) ក្នុងគោលបំណងធ្វើយ៉ាងណាឱ្យប្រព័ន្ធស្ថិតិកាន់តែស្របគ្នាទៅនឹងស្តង់ដារអន្តរជាតិ។ អង្គការសហប្រជាជាតិក៏គាំទ្រដល់ការប្រមូលទិន្នន័យស្ថិតិសំខាន់ៗ តាមរយៈការជំរឿនថ្នាក់ជាតិ ការអង្កេតប្រជាសាស្ត្រ ការអង្កេតសង្គមសេដ្ឋកិច្ច និងប្រព័ន្ធទិន្នន័យរដ្ឋបាល

---

[1] ព័ត៌មានបន្ថែម អាចរកបាន ក្នុងការពិនិត្យឡើងវិញស្ម័គ្រចិត្តថ្នាក់ជាតិរបស់កម្ពុជា ឆ្នាំ ២០១៩
https://www.kh.undp.org/content/cambodia/en/home/library/environment_energy/cambodia_s-voluntary-national-review-2019.html

ដែលផ្តល់នូវទិន្នន័យប្រកបដោយគុណភាព សម្រាប់ប្រើប្រាស់ក្នុងការពិនិត្យតាមក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិ និងដាក់ចេញនូវទិសដៅគោលនយោបាយផងដែរ។ នេះរួមមានការការគាំទ្រដល់ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍ស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់រដ្ឋាភិបាល តាមរយៈការបង្កើតនូវវេទិកាថ្នាក់ជាតិមួយ សម្រាប់ជួយឱ្យក្រសួងស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាលរៀបចំរបាយការណ៍ និងផ្ទោះប្តូរទិន្នន័យសូចនាករស្តីពីការអភិវឌ្ឍជាតិ ឬគោលដៅអភិវឌ្ឍន៍ដោយចីរភាព ដែលហៅកាត់ថា CAMSTAT ដែលក្នុងនោះមានបញ្ចូលផតថល សម្រាប់តាមដានគោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា ឬគោលដៅអភិវឌ្ឍន៍ដោយចីរភាពផងដែរ។ នៅក្នុងបរិបទនៃការរាតត្បាតជាសកលនាពេលបច្ចុប្បន្ននេះ ទិន្នន័យដែលអាចជឿជាក់បាន មានសារៈសំខាន់ និងចាំបាច់សម្រាប់គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងពន្លឿនការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព ដើម្បីផ្តល់លទ្ធភាពឱ្យប្រទេសកម្ពុជានៅតែស្ថិតលើមាគ៌ាត្រឹមត្រូវ ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព។

រួមគ្នាជាមួយនឹងដៃគូ អង្គការសហប្រជាជាតិបានធ្វើការវាយតម្លៃបែបរហ័ស និងការអង្កេតជាច្រើន ដើម្បីប្រមូលទិន្នន័យ ឈ្វេងយល់ឱ្យកាន់តែប្រសើរពីផលប៉ះពាល់ដែលការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ បង្កឡើងផ្សេងៗគ្នា មកលើស្ថានភាពសុខភាព សង្គម និងជាពិសេស ស្ថានភាពសេដ្ឋកិច្ចរបស់ក្រុមងាយរងគ្រោះ។ ដំណើរការនេះ រួមមាន ការវាយតម្លៃ និងការអង្កេតលើផលប៉ះពាល់ ដើម្បីប្រមូលទិន្នន័យស្តីពីផលប៉ះពាល់ដែលការរាតត្បាតជាសកលបង្កលើកុមារ ស្ត្រី យុវជន ជនមានពិការភាព អ្នករស់នៅជាមួយមេរោគ/ឆ្លងជំងឺអេដស៍ សុខភាពផ្លូវភេទ និងបន្តពូជ ពលករទេសន្តរប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍ កម្មករកាត់ដេរ ពលករក្រៅប្រព័ន្ធ ក៏ដូចជាសហគ្រាសខ្នាតតូចនិងមធ្យម។ ការអង្កេតជាច្រើនត្រូវបានធ្វើឡើងជាច្រើនជុំនិងច្រើនដង និងបានរួមចំណែកផ្តល់ជាព័ត៌មានដល់ការធ្វើគោលនយោបាយ និងការកែសម្រួលកម្មវិធីរបស់រដ្ឋាភិបាល ដើម្បីអាចឆ្លើយតបកាន់តែប្រសើរទៅនឹងស្ថានភាពកូវីដ-១៩ ដែលបន្តមានការប្រែប្រួល។

អង្គការសហប្រជាជាតិក៏កំពុងរួមចំណែកការផ្តល់ទិន្នន័យប្រកបដោយគុណភាព តាមរយៈការប្រមូលទិន្នន័យតាមខ្នង់ផ្ទះ ដែលធ្វើឡើងជាទៀងទាត់ ដើម្បីវាស់វែងការវិវឌ្ឍនៃស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ព្រមទាំងប្រសិទ្ធភាពនៃវិធានការកាត់បន្ថយផលប៉ះពាល់នៅកម្ពុជា។ អង្គការសហប្រជាជាតិបានធ្វើការពិនិត្យតាមដានតម្លៃ និងស្ថានភាពទីផ្សារពីចម្ងាយ ដោយសហការជាមួយនឹងការិយាល័យទីផ្សារកសិកម្ម (AMO) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងបានផលិតរបាយការណ៍ពិនិត្យតាមដានប្រចាំខែ (របាយការណ៍បច្ចុប្បន្នភាពស្តីពីទីផ្សារកម្ពុជា) ដែលផ្តល់នូវទិន្នន័យ និងព័ត៌មានស៊ីជម្រៅអំពីនិន្នាការតម្លៃ ដំណើរការទីផ្សារ និងខ្សែប្រវាក់ផ្គត់ផ្គង់ផលិតកម្មកសិកម្ម ដើម្បីឈ្វេងយល់ពីស្ថានភាពទីផ្សារទូទៅ និងផលប៉ះពាល់មកលើគ្រួសារនានានៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការឆ្លើយតបគោលនយោបាយរបស់រដ្ឋាភិបាល។ អង្គការសហប្រជាជាតិប្រមូលទិន្នន័យផលិតកម្មកសិកម្មប្រចាំខែនៅកម្ពុជា ដើម្បីផ្តល់ការជូនដំណឹងជាមុន តាមរយៈប្រព័ន្ធផ្តល់ព័ត៌មាន និងប្រកាសអាសន្ននៅកម្រិតសកល។ ការពិនិត្យតាមដាននេះនៅតែបន្តធ្វើនៅក្នុងពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ និងបានផ្តល់នូវព័ត៌មានជារួមអំពីសូចនាករការសង្កេតផែនដី (Earth Observation Indicators) ដែលក្នុងនោះរួមមានសូចនាកររដូវ សូចនាកររុក្ខជាតិ និងសូចនាករកម្ពស់ទឹកភ្លៀងជាដើម។

អង្គការសុខភាពពិភពលោក ដែលជាទីភ្នាក់ងារសហប្រជាជាតិ និងក្រសួងសុខាភិបាលកម្ពុជា រៀបចំរបាយការណ៍អំពីស្ថានភាពកូវីដ-១៩ជាប្រចាំ ដើម្បីរំលេចឱ្យឃើញពីការអភិវឌ្ឍហើយចុងក្រោយបំផុតនៃការឆ្លើយតបរបស់

ប្រព័ន្ធសុខាភិបាលចំពោះជំងឺកូវីដ-១៩។ ចាប់តាំងពីការផ្ទុះការឆ្លងរាតត្បាតជាសកលនេះមក អង្គការសហប្រជាជាតិក៏បានគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការតាមដានចំនួនពលករទេសន្តប្រវេសក៍កម្ពុជាដែលបានធ្វើមាតុភូមិនិវត្តន៍ និងស្ថានភាពនៅតាមបណ្ដោយព្រំដែន ក៏ដូចជានៅតាមមណ្ឌលចត្តាឡីស័ក ដើម្បីផ្តល់ព័ត៌មានសម្រាប់រៀបចំគោលនយោបាយឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាព។ អង្គការសហប្រជាជាតិក៏កំពុងអនុវត្តកម្មវិធីជំនួយសង្គមឆ្លើយតបចំពោះវិបត្តិផងដែរ តាមរយៈការផ្សារភ្ជាប់ទំនាក់ទំនងរវាងទិន្នន័យគ្រួសារក្រីក្រជាមួយនឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធគ្រប់គ្រងក្រុមអន្តរជាតិ។ លើសពីនេះ ក៏មានការផ្តល់ការគាំទ្រដល់ប្រព័ន្ធគ្រប់គ្រងព័ត៌មានជាច្រើន ដូចជា ប្រព័ន្ធការគ្រប់គ្រងព័ត៌មានស្តីពីការការពារកុមារ និងវេទិកាសម្រាប់ការពិនិត្យតាមដានផលប៉ះពាល់ និងស្ថានភាពភ្លាមៗ (PRISM) ជាដើម។

អង្គការសហប្រជាជាតិដែលបានសហការជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីការកសាងនូវម៉ូដែល (models) ដំបូងៗ សម្រាប់ធ្វើការប៉ាន់ប្រមាណពីផលប៉ះពាល់សង្គម និងសេដ្ឋកិច្ច ដែលបង្កឡើងដោយសារជំងឺកូវីដ-១៩។ ការងារនេះបានបង្ហាញឃើញថា កញ្ចប់ថវិកាសង្គ្រោះដែលមានបញ្ចូលការគាំពារសង្គម មិនត្រឹមតែធ្វើឱ្យ ផ.ស.ស កើនឡើងប៉ុណ្ណោះទេ ប៉ុន្តែក៏រួមចំណែកកាត់បន្ថយភាពក្រីក្រ និងភាពគ្មានការងារធ្វើផងដែរ។ ការវិភាគបន្តទៀតបង្ហាញឱ្យឃើញថា ការថយចុះការទទួលបានការអប់រំ ដោយសារស្ថានភាពនៃការរាតត្បាតជាសកល នាំឱ្យសន្ទស្សន៍អភិវឌ្ឍធនធានមនុស្សរបស់កម្ពុជា ធ្លាក់ចុះផងដែរ។

ដើម្បីបង្កើនលទ្ធភាពប្រើប្រាស់ទិន្នន័យឱ្យបានទូលំទូលាយ អង្គការសហប្រជាជាតិបានបង្កើតនូវផ្ទាំងទិន្នន័យរបាយការណ៍សាធារណៈមួយ ដែលមានផ្ទុកនូវរបាយការណ៍ស្រាវជ្រាវ និងវាយតម្លៃដែលត្រូវបានបោះពុម្ពផ្សាយចុងក្រោយ និងដែលនឹងត្រូវបោះពុម្ពផ្សាយនាពេលខាងមុខ ស្តីពីប្រទេសកម្ពុជាដែលប្រមូលពីដៃគូនានា។ ផ្ទាំងទិន្នន័យនេះក៏មានបញ្ចូលការស្រាវជ្រាវអំពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ផងដែរ។ គិតត្រឹមថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០២១ ការវាយតម្លៃដែលត្រូវបានបញ្ចប់ និងដែលកំពុងបន្តធ្វើចំនួន ១៦៨ ត្រូវបានបញ្ចូលទៅក្នុងនៅផ្ទាំងទិន្នន័យនេះ។ ផ្ទាំងទិន្នន័យនេះបង្ហាញព័ត៌មានដែលបានពីរបាយការណ៍នានាក្នុងទម្រង់ជារូបភាព និងជាការវិភាគដែលងាយស្រួលយល់។ ផ្ទាំងទិន្នន័យនេះជួយវាយតម្លៃ និងកំណត់ដឹងពីចំណេះដឹងដែលនៅខ្វះខាត បង្កើតនូវចំណុចក្តៅសម្រាប់តាមដានវឌ្ឍនភាពស្របតាមរបៀបវារៈអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ ២០៣០។

ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ រំលេចឱ្យឃើញពីបញ្ហាប្រឈម និងភាពងាយរងគ្រោះ ក្នុងការផលិតទិន្នន័យ និងប្រព័ន្ធទិន្នន័យ។ រាជរដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពីដៃគូ បានខិតខំប្រឹងប្រែងផលិតទិន្នន័យ និងភ័ស្តុតាងសម្រាប់ធ្វើការសម្រេចចិត្តគោលនយោបាយ និងកែសម្រួលកម្មវិធីនានា។ ក្នុងន័យនេះ អង្គការសហប្រជាជាតិសូមលើកទឹកចិត្តឱ្យអាជ្ញាធរបន្តកិច្ចខិតខំប្រឹងប្រែងពង្រឹងប្រព័ន្ធទិន្នន័យ និងស្ថិតិជាតិ ដើម្បីជានាយ៉ាងណាឱ្យទិន្នន័យកាន់តែអាចរួមចំណែកមិនទុកនរណាម្នាក់ចោល ក៏ដូចជាលើកកម្ពស់សមភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។ ដើម្បីធ្វើកិច្ចការនេះប្រកបដោយប្រសិទ្ធភាព ប្រព័ន្ធផលិតទិន្នន័យត្រូវឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាព និងកាន់តែឆាប់រហ័សចំពោះបរិយាកាសដែលកំពុងមានការផ្លាស់ប្តូរ និងត្រូវរំពឹងទុកជាមុនឱ្យកាន់តែប្រសើរពីហានិភ័យដែលអាចកើតមានឡើង។ អង្គការសហប្រជាជាតិលើកទឹកចិត្តឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងនវានុវត្តន៍ និងប្រភពទិន្នន័យថ្មីៗឱ្យបានកាន់តែប្រសើរ ដើម្បីផ្គត់ផ្គង់ទិន្នន័យឱ្យកាន់តែទាន់ពេលវេលា។ អង្គការសហប្រជាជាតិក៏លើកទឹកចិត្តឱ្យអាជ្ញាធរលើកកម្ពស់ចំណេះដឹងអំពីទិន្នន័យ និងអភិបាលកិច្ចទិន្នន័យផងដែរ។ តាមរយៈការបង្ហាញឱ្យឃើញពីតួនាទីដ៏សំខាន់របស់ទិន្នន័យ ក្នុងការឆ្លើយតបចំពោះការរាតត្បាតជាសកល អង្គការសហប្រជាជាតិជំរុញឱ្យអាជ្ញាធរជានាឱ្យមានតុល្យភាពរវាងក្នុងការការពារសុខភាពសាធារណៈ និងសិទ្ធិរក្សាភាពជាឯកជន។ ការរក្សាភាពជាឯកជននៃទិន្នន័យ និងការការពារ

ព័ត៌មានផ្ទាល់ខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយ អាចសម្រេចបានតាមរយៈការដាក់ចេញនូវវិធានការច្បាប់ និងគោលនយោបាយសមស្រប។ ក្នុងពេលជាមួយគ្នា ការរក្សាតុល្យភាព និងការគោរពសារៈសំខាន់នៃការធានាតម្លាភាព និងភាពងាយស្រួលប្រើប្រាស់ទិន្នន័យ ដើម្បីប្រយោជន៍សាធារណៈ ក៏មានសារសំខាន់ផងដែរ។ ជាការសំខាន់ណាស់ដែលចាំបាច់ត្រូវធ្វើការគ្រប់គ្រងទិន្នន័យដោយប្រើប្រាស់អភិក្រមគ្រប់ជ្រុងជ្រោយទូទាំងរដ្ឋាភិបាល ដោយត្រូវជំរុញឱ្យមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ និងដៃគូទាំងអស់នៅគ្រប់វិស័យ។ ចាំបាច់ត្រូវមានការបង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីជម្រះរបៀបប្រមូលទិន្នន័យដាច់ដោយឡែកពីគ្នា និងគួរផ្តល់អាទិភាពលើការបង្កើនសមត្ថភាពប្រមូលទិន្នន័យបែងចែកតាមប្រភេទ ដើម្បីធានាឱ្យមានការបញ្ចូលក្រុមអ្នកងាយរងគ្រោះដែលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ ដោយសារការរាតត្បាតជាសកល។

អង្គការសហប្រជាជាតិនឹងបន្តធ្វើការងារជាមួយនឹងរាជរដ្ឋាភិបាល និងដៃគូដទៃទៀត ដើម្បីបង្កើនភាពអ៊ីរ៉ុបបានភាពទាន់ពេលវេលា និងការប្រើប្រាស់ទិន្នន័យ និងស្ថិតិប្រកបដោយគុណភាព ដែលចាំបាច់សម្រាប់ឆ្លើយតបចំពោះការរាតត្បាតជាសកល វិបត្តិនាពេលអនាគត និងដើម្បីពន្លឿនសកម្មភាពឈានទៅសម្រេចគោលដៅដោយចីរភាព។

####

ឯកសារព័ត៌មានស្តីពីការឆ្លើយតបរបស់អង្គការសហប្រជាជាតិនៅកម្ពុជាចំពោះបញ្ហាកូវីដ-១៩ គឺជាឯកសារផ្លូវការដែលផលិតដោយអង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីផ្សព្វផ្សាយជូនអ្នកសារព័ត៌មាន និងដៃគូដទៃទៀត។ ឯកសារទាំងនេះត្រូវបានរៀបចំដោយការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនង និងស្វែងរកការគាំទ្រនៃការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា តាមរយៈអ៊ីមែល៖ sreysros.keo@un.org។